## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ១៣ "ឈ"/១២៩

-ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ ១០៩៣

ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៧

-សំណុំរឿងស៊ើបសួរលេខ ១១៥១

ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៧

-សំណុំរឿងជំនុំជម្រះលេខ ១១១៨

ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណ: នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ០០ នាទី ព្រឹក នៅសាលសវនាការទី ០១ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមជំនុំជម្រះសាលាដំបូងខេត្តសៀមរាប

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះលើបណ្តឹងទាស់នឹងសាលក្រមកំបាំងមុខលេខ ១១០ "ញ" ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២០ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ១០៩៣ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **សំអុល** ភេទប្រុស អាយុ ៥៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted]ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៤ មុខរបរ កសិករ ប្រពន្ធឈ្មោះ[redacted] សារុធ មានកូនចំនួន ៥នាក់ ឪពុកឈ្មោះ[redacted]រស់ (ស) ម្តាយឈ្មោះ[redacted]ភត (ស) ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។ (ក្រៅឃុំ)

មានលោកមេធាវី [redacted]ការពារសិទ្ធអោយជនជាប់ចោទ (**វត្តមាន**)

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធអោយជនជាប់ចោទ (**អវត្តមាន**)

២-ឈ្មោះ [redacted]**ឈង់** ភេទប្រុស អាយុ ៦៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ គ្មាន មុខរបរ គ្មាន ប្រពន្ធឈ្មោះ[redacted]ម៉ាលី មានកូនចំនួន ៧នាក់ ឪពុកឈ្មោះ[redacted]ឈិន (ស) ម្តាយឈ្មោះ[redacted]ពូ (ស) ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។ (ក្រៅឃុំ)

មានលោកមេធាវី [redacted]ការពារសិទ្ធអោយជនជាប់ចោទ (**វត្តមាន**)

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធអោយជនជាប់ចោទ (**អវត្តមាន**)

៣-ឈ្មោះ [redacted] **ចន្ថា** ភេទប្រុស អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ **ថ្នាក់ទី៨** មុខរបរ **ជាងនាឡិកា** ប្រពន្ធឈ្មោះ [redacted] វណ្ណី មានកូនចំនួន ៤នាក់ ឪពុកឈ្មោះ[redacted] ប៊ុន (ស) ម្តាយឈ្មោះ[redacted]ណោត (ស) ប្រវត្តិនៃការផ្តន្ទាទោស ៦ខែ (ប្តូង់)។ (ក្រៅឃុំ)

មានលោកមេធាវី [redacted] ការពារសិទ្ធអោយជនជាប់ចោទ (វត្តមាន)

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធអោយជនជាប់ចោទ (អវត្តមាន)

៤-ឈ្មោះ [redacted] ស្រូវណោះ ភេទប្រុស អាយុ ៦៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិវត្ត [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ ថ្នាក់ទី១២ មុខរបរ យោធិនចូលនិវត្ត ប្រពន្ធឈ្មោះ [redacted] រឿង មានកូនចំនួន ៨នាក់ ឪពុកឈ្មោះ [redacted] ចំរើន (ស) ម្តាយឈ្មោះ [redacted] យឿន (ស) ប្រវត្តិនៃការផ្តន្ទាទោស គ្មាន។ (ក្រៅឃុំ)

មានលោកមេធាវី [redacted] ការពារសិទ្ធអោយជនជាប់ចោទ (វត្តមាន)

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធអោយជនជាប់ចោទ (អវត្តមាន)

ជាប់ចោទពីបទៈ "**ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងបទធ្វើឲ្យធាត់ដំណើរលើសេចក្តីសម្រេចរបស់តុលាការ**" ប្រព្រឹត្តនៅភូមិស្នាសង្គ្រាម ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង់ ខេត្តសៀមរាប និងភូមិសរសើ ឃុំតែ្បង ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ **មាត្រា ២៥៣** នៃច្បាប់ភូមិបាល និង**មាត្រា ៥២៣** នៃក្រមព្រហ្មទណ្ឌ ។

## ដើមបណ្តឹងរដ្ឋប្បវេណី

-ឈ្មោះ [redacted] **ចាន់រដ្ឋា** ភេទប្រុស អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅលេខ២ ផ្លូវលេខ២១១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធអោយដើមបណ្តឹងរដ្ឋប្បវេណី (វត្តមាន)

មានលោក [redacted] ជាមេធាវីការពារសិទ្ធអោយដើមបណ្តឹងរដ្ឋប្បវេណី (អវត្តមាន)

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងឆ្នាំ ២០១៤ រហូតដល់ឆ្នាំ២០១៧ មានករណីវិវាទដីធ្លីស្ថិតនៅភូមិស្នាសង្គ្រាម ឃុំ បល្ល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប និងស្ថិតនៅភូមិសរសើ ឃុំតែ្បង ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដោយដីវិវាទមានទំហំ ៨៤ ហិកតា (ប៉ែតសិបបួន) ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] វ៉ានី ដែលបានប្តូរជាមួយនឹង កងវិស្វកម្មសម្តេចតេជោ ហើយបានកាន់កាប់ជាកម្មសិទ្ធិតាំងពីពេលនោះ តែមានមនុស្សចំនួន ១០ នាក់ បាន មករំលោភយកដីនោះ ទោះបីម្ចាស់ដីហាមឃាត់ក៏ជនទាំង ១០ នាក់នោះមិនស្តាប់ ឬឈប់សកម្មភាពរបស់ពួក គេដែរ ។ នៅក្នុងអំឡុងឆ្នាំ ២០១៤ ឈ្មោះ [redacted] ចិន្តា (បច្ចុប្បន្ននេះ បានទទួលមរណភាពហើយ) បានដាក់ពាក្យបណ្តឹងនៅសាលាដំបូងខេត្តសៀមរាប ដោយតុលាការបានចេញដីកាសម្រេចរក្សាការពារលេខ ៣៥២ ពស.តរវ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ ហាមឃាត់មិនឲ្យជនទាំង ១០ នាក់ ដែលរំលោភយកដីរបស់ឈ្មោះ [redacted] វ៉ានី មិនឲ្យធ្វើសកម្មភាពគ្រប់បែបយ៉ាងលើទីតាំងដីទំនាស់ ដោយមានកំណត់ហេតុអនុវត្តលេខ ៣០១ ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៤ ប៉ុន្តែ ចាប់តាំងពីពេលនោះមក ឈ្មោះ [redacted] វណ្ណា, ឈ្មោះ [redacted] សំអុល, ឈ្មោះ [redacted] ឈង់ និងឈ្មោះ [redacted] ស្រណោះ នៅតែបន្តសកម្មភាពធ្វើអ្វីផ្សេងៗនៅលើដីនោះ រហូតដោយមិនខ្លាច ឬ គោរពដីកាសម្រេចរបស់តុលាការនោះឡើយ រហូតដល់សព្វថ្ងៃនេះ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១១០ "ញ" ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២០ របស់សាលា ដំបូងខេត្តសៀមរាបបានសម្រេចសេចក្តីដូចខាងក្រោម៖



Scanned with CamScanner

**១-ផ្តន្ទាទោស**

ក-ឈ្មោះ [redacted] **សំអុល** ភេទប្រុស អាយុ ៥៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០១ (មួយ) ឆ្នាំ ។

ខ-ឈ្មោះ [redacted] **ឈយ់** ភេទប្រុស អាយុ ៦៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០១ (មួយ) ឆ្នាំ ។

គ-ឈ្មោះ [redacted] **ទណ្ណា** ភេទប្រុស អាយុ ៤៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០១ (មួយ) ឆ្នាំ ។

ឃ-ឈ្មោះ [redacted] **ស្រូវឈោះ** ភេទប្រុស អាយុ ៦៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០១ (មួយ) ឆ្នាំ ។

ពីបទ: **"ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងបទ ធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ"** ប្រព្រឹត្តនៅភូមិស្នាសង្គ្រាម ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង់ ខេត្តសៀមរាប និងភូមិសរសើ ឃុំតែ្បង ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ **មាត្រា ២៥៣** នៃច្បាប់ភូមិបាល និង**មាត្រា ៥៧ មាត្រា ៥២៣** នៃក្រមព្រហ្មទណ្ឌ ។

**២-បង្គាប់ឲ្យ**ឈ្មោះ [redacted] **សំអុល** ភេទប្រុស អាយុ ៥៥ឆ្នាំ ,ឈ្មោះ [redacted] **ឈយ់** ភេទប្រុស អាយុ ៧០ឆ្នាំ ,ឈ្មោះ [redacted] **ទណ្ណា** ភេទប្រុស អាយុ ៤៧ឆ្នាំ និងឈ្មោះ [redacted] **ស្រូវឈោះ** ភេទប្រុស អាយុ ៦៨ឆ្នាំ រួមគ្នាសងសំណងជម្ងឺចិត្តទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ទី ចាន់រដ្ឋា ភេទប្រុស អាយុ ៣៨ឆ្នាំ សរុបចំនួន ២០,០០០,០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះបដិសេធចោល តាម**មាត្រា ៣៥៥** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២០ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

## នាពេលសវនាការ

-ក្រឡាបញ្ជីអានសេចក្តីចម្លងបណ្តឹងទាស់លេខ ៤៥៨ ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] **សំអុល** ,ឈ្មោះ [redacted] **ឈយ់** ,ឈ្មោះ [redacted] **ទណ្ណា** និងឈ្មោះ [redacted] **ស្រូវឈោះ** សុំប្តឹងទាស់លើសាលក្រមព្រហ្មទណ្ឌលេខ ១១០ "ញ" ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២០ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សំអុល** បានឆ្លើយនៅសវនាការថា៖ មូលហេតុដែលខ្ញុំនៅតែរក្សាកន្លែងអាស្រ័យផលលើដីនោះ ព្រោះខ្លួនមានលិខិតរបស់មេភូមិ ហើយខ្លួនអាស្រ័យផលលើដីខ្លួននោះរហូតមក ខ្លួនមិនបានធ្វើលើដី [redacted] វ៉ាន់នី ទេ។ ហើយខ្លួនត្រូវបានថ្នាក់ខេត្តគេហៅដោះស្រាយជាមួយ [redacted] វ៉ាន់ ហើយ។ ចំពោះដីកាសម្រេចរក្សាការពារ ដែលហាមឃាត់ខ្លួននោះ គឺមិនបានយល់ទេ ដោយខ្លួនសំអាងលើដំណាំដែលខ្លួនមានស្រាប់។ សព្វថ្ងៃចំពោះដីនោះខ្លួនលក់បាត់ ហើយឈប់នៅទីនោះហើយ។ ពេលដែលគេចុះអនុវត្តដីកានោះខ្លួនបានចូលរួមតែខ្លួនមិនព្រមផ្តិតមេដៃព្រោះខ្លាចគេឲ្យផ្តិចមេដៃអោយដីគេ។ ដីដែលខ្លួនកាន់កាប់មានចំនួនប្រហែលជា ៣ហិចតា ដោយខ្លួនកាន់កាប់នៅឆ្នាំ២០០៤ មកដោយខ្លួនធ្វើដំណាំលើដីនោះជាប់រហូតដល់មានរឿង នៅឆ្នាំ ២០០៨ ហើយនៅក្នុងឆ្នាំ២០១៤ ទើបមានដីការក្សាការពារ។

**-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឈយ់** បានឆ្លើយនៅសវនាការថា៖ ដីនោះខ្លួនទិញតាំងពីឆ្នាំ ១៩៨៧ ហើយដីនោះជាកម្មសិទ្ធិ ខ្លួន ហើយសាលាខេត្តក៏ទទួលស្គាល់ថាជាដីរបស់ខ្លួន ហើយនៅឆ្នាំ២០១៨ ខ្លួនបាន

លក់ និងឈប់នៅលើដីនោះទៀតហើយ។ បច្ចុប្បន្ននេះខ្លួនមិននៅលើដីនោះទៀតទេ។ ដីខ្លួនកាន់កាប់តាំងពីឆ្នាំ ១៩៩៧ ប្រហែល ១,៥ហិចតា ប៉ុន្តែខ្លួនជួលឱ្យឈ្មោះ [redacted] វណ្ណា ធ្វើការដាំដុះលើដីនោះតាំងពីពេលនោះមក។

**-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ទណ្ណា** បានឆ្លើយនៅសវនាការថាៈ តាំងពីខ្លួនទិញមកខ្លួនធ្វើការបង្កើនផលលើដីនោះរហូត ហើយមានគេមកធ្វើលើដីខ្លួន ដោយខ្លួនក៏បានសុំរក្សាការពារវិញដែរ។ ចំពោះដីនោះខ្លួនលក់ឱ្យគេបាត់ហើយ។ ពេលដែលគេចុះអនុវត្តដីការការពារពួកខ្លួនមិនទទួលស្គាល់។ ខ្លួនលក់ដីឱ្យគេនៅពេលដែលគេចេញដីការក្សាការពារ ហើយខ្លួនលក់ដីនោះនៅឆ្នាំ២០១៧។ ខ្លួនទិញដីគេតាំងពីឆ្នាំ២០០៦ ហើយខ្លួនអាស្រ័យផលរហូតមក។

**-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រុះណេះ** បានឆ្លើយនៅសវនាការថាៈ ខ្លួនបានទិញដីនោះ ពីម្ចាស់ដើម ដោយមានអាជ្ញាធរភូមិឃុំគេទទួលស្គាល់។ ហើយចំពោះដី ៨៤ហិចតា នោះ គឺមានក្រោយខ្លួនទេ។ ខ្លួននៅលើដីនោះតាំងពីឆ្នាំ១៩៩៧ ដល់ ២០១៧។ ហើយសព្វថ្ងៃខ្លួនចេញពីដីនោះហើយ។ ខ្លួនកាន់កាប់ដោយទិញពីឆ្នាំនោះ នៅឆ្នាំ២០០៤ ដោយខ្លួនធ្វើស្រែចំការលើដីនោះរហូតមក។ ចំពោះដីការក្សាការពារពួកខ្លួនបានចូលរួមហើយគេអានឱ្យស្តាប់ដែរប៉ុន្តែពួកខ្លួនមិនទទួលស្គាល់ទេ។ ក្រោយពីគេអនុវត្តដីការក្សាការពារនោះ មកគឺពួកខ្លួននៅតែកាន់កាប់ធ្វើលើដីនោះរហូតមកដល់ឆ្នាំ២០១៨ ទើបពួកខ្លួនមិនទទួលស្គាល់ដីកានោះ ហើយបានប្តឹងជំទាស់លើដីកានោះ ហើយតុលាការរុញឱ្យទៅដោះស្រាយនៅសាលាខេត្ត។

## សេចក្តីសន្និដ្ឋានរបស់ភាគីនាពេលសវនាការ

**-លោកស្រីមេធាវី [redacted]** ការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថាៈ ក្រោយពីបានពិភាក្សាដេញដោល ឃើញថាជនជាប់ចោទទាំង ៤នាក់ គឺជាការឆ្លើយដោះសារគេចវេស ពីការទទួលខុសត្រូវ ព្រោះពួកគាត់ដឹងថាដីនោះ ត្រូវបានតុលាការបានហាមឃាត់រួចហើយ តែពួកគាត់នៅតែបំពាន ហេតុដូច្នេះស្នើសុំតម្កល់សាលក្រមមុនទុកជាបានការដដែល។

**-លោកមេធាវី [redacted] ការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា**ៈក្រោយពីបានពិភាក្សាដេញដោល ខ្លួនយល់ព្រមឯកភាពតាមសេចក្តីសន្និដ្ឋានរបស់លោកស្រីមេធាវី ភ្លូង ស្រីខ្សែងទាំងស្រុង។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈ** ក្រោយពីបានស្តាប់ ចម្លើយរបស់ជនជាប់ចោទ និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងពិនិត្យភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿងរួចមកឃើញថា ជនជាប់ចោទទាំង ៤រូបនេះ គឺពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហេតុដូច្នេះតំណាងអយ្យការស្នើសុំ តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១០ "ញ" ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាបទុកជាបានការដដែល។

**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថាៈ** តុលាការចោទប្រកាន់កូនក្តីខ្លួន ២បទល្មើស ឃើញថារឿងក្តីនេះត្រូវបានសាលាខេត្តទទួលស្គាល់របស់ខេត្ត ប៉ុន្តែក្នុងរឿងនេះពុំទាន់មានឯកសារណាមួយមកបញ្ជាក់ទេ។ ហើយនៅក្នុងអង្គហេតុនេះពុំមានការប្រើហិង្សាទេ ដោយកូនក្តីរបស់ខ្លួនបានកាន់កាប់លើដីនោះ ពុំមែនជាដីដើមបណ្តឹងទេ។ ទាក់ទងការកាន់កាប់ជាក់ស្តែង គឺកូនក្តីខ្លួនជាអ្នកកាន់កាប់ មិនមែនដើមបណ្តឹងកាន់កាប់ទេ។ ទាក់ទងដីការក្សាការពារ គឺមានចំនួន២ ដោយដីកាទី១ ឱ្យកូនក្តីខ្លួនអាស្រ័យផល ហើយកូនក្តីខ្លួនក៏បានអាស្រ័យផល លើដីនោះតាមដីកា។ ដោយឡែកចំពោះដីកាសម្រេចទី២ គឺសម្រេចផ្សេង ឃើញថាកូនក្តីខ្លួនបានអនុវត្តតាមដីការក្សាការពារទី១ ដោយដីកាទី២ ចេញក្រោយមិនអាច យកមកអនុវត្តបានទេ។



Scanned with CamScanner

ដូចនេះគ្មានភស្តុតាងណាមួយ មកដាក់បន្ទុកដើម្បីចោទប្រកាន់កូនក្តីរបស់ខ្លួនតាមសាលក្រមមុនទេ។ ហេតុដូច្នេះសុំឱ្យកូនក្តីខ្លួនរួចផុតបទចោទ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រណោះ ៖ ខ្លួនសុំរួចផុតចោទប្រកាន់។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ឈយង់ ៖ ខ្លួនសុំរួចផុតចោទប្រកាន់។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ៖ ខ្លួនសុំរួចផុតចោទប្រកាន់។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សំអុល ៖ ខ្លួនសុំរួចផុតចោទប្រកាន់។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

**១**-ជនជាប់ចោទឈ្មោះ [redacted] ស្រណោះ ឈ្មោះ [redacted] ឈយង់ ឈ្មោះ [redacted] វណ្ណា ឈ្មោះ [redacted] សំអុល បានចូលខ្លួនមកបង្ហាញខ្លួននៅពេលសវនាការ តាមការកោះហៅរបស់តុលាការ ហេតុដូច្នេះ គប្បីតុលាការលើកយកបណ្តឹងទាស់ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រណោះ ឈ្មោះ [redacted] ឈយង់ ឈ្មោះ [redacted] វណ្ណា ឈ្មោះ [redacted] សំអុល លើសាលក្រមព្រហ្មទណ្ឌលេខ ១១០ "ញ" ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០២០ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល យកមកធ្វើការជំនុំជម្រះ។

**២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សំអុល** ដែលបានឆ្លើយថា៖ មូលហេតុដែលខ្លួននៅតែរក្សាកន្លែងអាស្រ័យផលលើដីនោះ ព្រោះខ្លួនមានលិខិតរបស់មេភូមិ ហើយខ្លួនអាស្រ័យផលលើដីខ្លួននោះរហូតមក ហើយ ខ្លួនមិនបានធ្វើលើដី [redacted] វ៉ាន់នី ទេ។ ហើយខ្លួនត្រូវបានថ្នាក់ខេត្តគេហៅដោះស្រាយជាមួយ [redacted] វ៉ាន់ ហើយ។ ចំពោះដីកាសម្រេចរក្សាការពារ ដែលហាមឃាត់ខ្លួននោះ គឺមិនបានយល់ទេ ដោយខ្លួនសំអាងលើដំណាំដែលខ្លួនមានស្រាប់។ សព្វថ្ងៃចំពោះដីនោះខ្លួនលក់បាត់ ហើយឈប់នៅទីនោះហើយ។ ពេលដែលគេចុះអនុវត្តដីកានោះខ្លួនបានចូលរួមតែខ្លួនមិនព្រមផ្តិតមេដៃព្រោះខ្លាចគេឱ្យផ្តិតមេដៃអោយដីគេ។ ដីដែលខ្លួនកាន់កាប់មានចំនួនប្រហែលជា ៣ហិចតា ដោយខ្លួនកាន់កាប់នៅឆ្នាំ២០០៤ មកដោយខ្លួនធ្វើដំណាំលើដីនោះជាប់រហូតដល់មានរឿងនៅឆ្នាំ២០០៨ ហើយនៅក្នុងឆ្នាំ២០១៤ ទើបមានដីការក្សាការពារ។ តុលាការយល់ថា ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សំអុល គឺពុំមានភស្តុតាងណាមួយមកបញ្ជាក់ឱ្យតុលាការជឿបានឡើយ។ ផ្ទុយទៅវិញបើតាមភស្តុតាងនៅក្នុងសំណុំរឿង អាចឱ្យតុលាការជឿបានថា ជនជាប់ចោទរូបនេះពិតជាបានប្រព្រឹត្តអំពើ **ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងបទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ** ប្រាកដមែន ហេតុដូច្នេះ គប្បីតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់។

**៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឈយង់** បានឆ្លើយនៅសវនាការថា៖ ដីនោះខ្លួនទិញតាំងពីឆ្នាំ ១៩៩៧ ហើយដីនោះជាកម្មសិទ្ធិ ខ្លួន ហើយសាលាខេត្តក៏ទទួលស្គាល់ថាជាដីរបស់ខ្លួន ហើយនៅឆ្នាំ២០១៨ ខ្លួនបាន

លក់ និងឈប់នៅលើដីនោះទៀតហើយ។ បច្ចុប្បន្ននេះខ្លួនមិននៅលើដីនោះទៀតទេ។ ដីខ្លួនកាន់កាប់តាំងពីឆ្នាំ ១៩៩៧ ប្រហែល ១,៥ហិចតា ប៉ុន្តែខ្លួនជួលឱ្យឈ្មោះ [redacted] វណ្ណា ធ្វើការដាំដុះលើដីនោះតាំងពីពេលនោះមក។ តុលាការយល់ថា ចម្លើយរបស់ជនជាប់ចោទ ឈ្មោះ [redacted] ឈង់ គឺពុំមានភស្តុតាងណាមួយមកបញ្ជាក់ឱ្យតុលាការជឿបានឡើយ។ ផ្ទុយទៅវិញបើតាមភស្តុតាងនៅក្នុងសំណុំរឿង អាចឱ្យតុលាការជឿបានថា ជនជាប់ចោទរូបនេះពិតជាបានប្រព្រឹត្តអំពើ **ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងបទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ** ប្រាកដមែន ហេតុដូច្នេះ គប្បីតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់។

**៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា** បានឆ្លើយនៅសវនាការថា៖ តាំងពីខ្លួនទិញមក ខ្លួនធ្វើការបង្កើនផលលើដីនោះរហូត ហើយមានគេមកធ្វើលើដីខ្លួន ដោយខ្លួនក៏បានសុំរក្សាការពារវិញដែរ។ ចំពោះដីនោះខ្លួនលក់ឱ្យគេបាត់ហើយ។ ពេលដែលគេចុះអនុវត្តដីការការពារពួកខ្លួនមិនទទួលស្គាល់។ ខ្លួនលក់ដីឱ្យគេនៅពេលដែលគេចេញដីការក្សាការពារ ហើយខ្លួនលក់ដីនោះនៅឆ្នាំ២០១៧។ ខ្លួនទិញដីគេតាំងពីឆ្នាំ២០០៦ ហើយខ្លួនអាស្រ័យផលរហូតមក។ តុលាការយល់ថា ចម្លើយរបស់ជនជាប់ចោទ ឈ្មោះ [redacted] វណ្ណា គឺពុំមានភស្តុតាងណាមួយមកបញ្ជាក់ឱ្យតុលាការជឿបានឡើយ។ ផ្ទុយទៅវិញបើតាមភស្តុតាងនៅក្នុងសំណុំរឿង អាចឱ្យតុលាការជឿបានថា ជនជាប់ចោទរូបនេះពិតជាបានប្រព្រឹត្តអំពើ **ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងបទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ** ប្រាកដមែន ហេតុដូច្នេះ គប្បីតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់។

**៥-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រណោះ** បានឆ្លើយនៅសវនាការថា៖ ខ្លួនបានទិញដីនោះ ពីម្ចាស់ដើម ដោយមានអាជ្ញាធរភូមិឃុំគេទទួលស្គាល់។ ហើយចំពោះដី ៨៤ហិចតា នោះ គឺមានក្រោយខ្លួនទេ។ ខ្លួននៅលើដីនោះតាំងពីឆ្នាំ១៩៩៧ ដល់ ២០១៧។ ហើយសព្វថ្ងៃខ្លួនចេញពីដីនោះហើយ។ ខ្លួនកាន់កាប់ដោយទិញពីឆ្នាំនោះ នៅឆ្នាំ២០០៤ ដោយខ្លួនធ្វើស្រែចំការលើដីនោះរហូតមក។ ចំពោះដីការក្សាការពារពួកខ្លួនបានចូលរួមហើយ គេអានឱ្យស្តាប់ដែរប៉ុន្តែពួកខ្លួនមិនទទួលស្គាល់ទេ។ ក្រោយពីគេអនុវត្តដីការក្សាការពារនោះ មកគឺពួកខ្លួននៅតែកាន់កាប់ធ្វើលើដីនោះរហូតមកដល់ឆ្នាំ២០១៨ ទើបពួកខ្លួនមិនទទួលស្គាល់ដីកានោះ ហើយបានប្តឹងជំទាស់លើដីកានោះ ហើយតុលាការរុញឱ្យទៅដោះស្រាយនៅសាលាខេត្ត។ តុលាការយល់ថា ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រណោះ គឺពុំមានភស្តុតាងណាមួយមកបញ្ជាក់ឱ្យតុលាការជឿបានឡើយ។ ផ្ទុយទៅវិញបើតាមភស្តុតាងនៅក្នុងសំណុំរឿង អាចឱ្យតុលាការជឿបានថា ជនជាប់ចោទរូបនេះពិតជាបានប្រព្រឹត្តអំពើ **ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងបទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ** ប្រាកដមែន ហេតុដូច្នេះ គប្បីតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់។

**៦-លោកស្រីមេធាវី [redacted] ការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា ៖** ក្រោយពីបានពិភាក្សាដេញដោល ឃើញថាជនជាប់ចោទទាំង ៤នាក់ គឺជាការឆ្លើយដោះសារគេចវេស ពីការទទួលខុសត្រូវ ព្រោះពួកគាត់ដឹងថាដីនោះ ត្រូវបានតុលាការបានហាមឃាត់រួចហើយ តែពួកគាត់នៅតែបំពាន ហេតុដូច្នេះស្នើសុំតម្កល់សាលក្រមមុនទុកជាបានការដដែល។ តាមរយៈការស្នើសុំរបស់ មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបែបនេះ តុលាការនឹងធ្វើការពិចារណា។



Scanned with CamScanner

៧-លោកមេធាវី [redacted] ការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្រោយពីបានពិភាក្សាវែញវោល ខ្លួនយល់ព្រមឯកភាពតាមសេចក្តីសន្និដ្ឋានរបស់លោកស្រីមេធាវី ភួង ស្រីឡែង ទាំងស្រុង។

**៨-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖** ក្រោយពីបានស្តាប់ ចម្លើយរបស់ជនជាប់ចោទ និង ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងពិនិត្យភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿងរួចមកឃើញថា ជនជាប់ចោទទាំង ៤រូបនេះ គឺពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហេតុដូច្នេះតំណាងអយ្យស្នើសុំ តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១០ “ញ” ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២០ របស់សាលដំបូងខេត្តសៀមរាបទុកជាបានការដដែល។ តាមរយៈការប្តឹងសុំរបស់តំណាងអយ្យការ បែបនេះ តុលាការនឹងធ្វើការពិចារណា។

**៩-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖** តុលាការចោទប្រកាន់កូនក្តីខ្លួន ២បទល្មើស ឃើញថារឿងក្តីនេះត្រូវបានសាលាខេត្តទទួលស្គាល់របស់ខេត្ត ប៉ុន្តែក្នុងរឿងនេះពុំទាន់មានឯកសារណាមួយមកបញ្ជាក់ទេ។ ហើយនៅក្នុងអង្គហេតុនេះពុំមានការប្រើហិង្សាទេ ដោយកូនក្តីរបស់ខ្លួនបានកាន់កាប់លើដីនោះ ពុំមែនជាដីដើមបណ្តឹងទេ។ ទាក់ទងការកាន់កាប់ជាក់ស្តែង គឺកូនក្តីខ្លួនជាអ្នកកាន់កាប់ មិនមែនដើមបណ្តឹងកាន់កាប់ទេ។ ទាក់ទងដីការក្សាការពារ គឺមានចំនួន២ ដោយដីកាទី១ ឱ្យកូនក្តីខ្លួនអាស្រ័យផល ហើយកូនក្តីខ្លួនក៏បានអាស្រ័យផល លើដីនោះតាមដីកា។ ដោយឡែកចំពោះដីកាសម្រេចទី២ គឺសម្រេចផ្សេង ឃើញថាកូនក្តីខ្លួនបានអនុវត្តតាមដីការក្សាការពារទី១ ដោយដីកាទី២ ចេញក្រោយមិនអាច យកមកអនុវត្តបានទេ។ ដូចនេះគ្មានភស្តុតាងណាមួយ មកដាក់បន្ទុកដើម្បីចោទប្រកាន់កូនក្តីរបស់ខ្លួនតាមសាលក្រមមុនទេ។ ហេតុដូច្នេះសុំឱ្យកូនក្តីខ្លួនរួចផុតបទចោទ។ តាមរយៈការស្នើសុំរបស់ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបែបនេះ តុលាការនឹងធ្វើការពិចារណា ។

១០-មានធាតុផ្សំបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើ៖

ក-ឈ្មោះ [redacted] **សំអុល** ភេទប្រុស អាយុ ៥៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted]ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៤ មុខរបរ កសិករ ប្រពន្ធឈ្មោះ[redacted]សារុធ មានកូនចំនួន ៥នាក់ ឪពុកឈ្មោ[redacted]រស់ (ស) ម្តាយឈ្មោះ[redacted] អាត (ស) ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។

ខ-ឈ្មោះ [redacted] **ឈយ់** ភេទប្រុស អាយុ ៦៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅ[redacted]ខេត្តសៀមរាប កម្រិតវប្បធម៌ គ្មាន មុខរបរ គ្មាន ប្រពន្ធឈ្មោះ[redacted] ម៉ាលី មានកូនចំនួន ៧នាក់ ឪពុកឈ្មោះ[redacted] ឈិន (ស) ម្តាយឈ្មោះ[redacted]ពូ (ស) ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។

គ-ឈ្មោះ [redacted]**ចណ្ណា** ភេទប្រុស អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូ[redacted]ខេត្តសៀមរាប កម្រិតវប្បធម៌ ថ្នាក់ទី៨ មុខរបរ ជាងនាឡិកា ប្រពន្ធឈ្មោះ [redacted]ភ្លី មានកូនចំនួន ៤នាក់ ឪពុកឈ្មោះ[redacted]ប៊ុន (ស) ម្តាយឈ្មោះ[redacted]ណោត (ស) ប្រវត្តិនៃការផ្តន្ទាទោស ៦ខែ (ប្លង់)។ (ក្រៅឃុំ)

ឃ-ឈ្មោះ [redacted] **ស្រូវណោះ** ភេទប្រុស អាយុ ៦៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted]ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្ត

សៀមរាប កម្រិតវប្បធម៌ ថ្នាក់ទី១២ មុខរបរ ឃោធិនចូលនិវត្ត ប្រពន្ធឈ្មោះ [redacted] អឿង មានកូនចំនួន ៩នាក់ ឪពុកឈ្មោះ [redacted] ចំរើន (ស) ម្តាយឈ្មោះ [redacted] យឿន (ស) ប្រវត្តិនៃការផ្តន្ទាទោស គ្មាន។

ពីបទ: "**ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងបទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ**" ប្រព្រឹត្តនៅភូមិស្នាសង្គ្រាម ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប និងភូមិសរសី ឃុំតែ្បង ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ **មាត្រា ២៥៣** នៃច្បាប់ភូមិបាល និង**មាត្រា ៥២៣** នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១. ទទួលយកពាក្យបណ្តឹងទាស់ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] **សំអុល** ភេទប្រុស អាយុ ៥៥ឆ្នាំ ,ឈ្មោះ [redacted] **ឈយ់** ភេទប្រុស អាយុ ៦៧ឆ្នាំ ,ឈ្មោះ [redacted] **ចន្ថា** ភេទប្រុស អាយុ ៤៧ឆ្នាំ និងឈ្មោះ [redacted] **ស្រេណោះ** ភេទប្រុស អាយុ ៦៨ ឆ្នាំ ទុកជាត្រឹមត្រូវតាមទម្រង់ តែខុសគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: **១១០ "ឮ"** ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប ទុកជាបានការទាំងមូល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សំអុល** ,ឈ្មោះ [redacted] **ឈយ់** ,ឈ្មោះ [redacted] **ចន្ថា** ,ឈ្មោះ [redacted] **ស្រេណោះ** និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២១ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**

[redacted] | [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

សៀមរាប,ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner